


# ឥទ្ធិពលនៃកំណើនសេដ្ឋកិច្ចលើវប្បធម៌នៅកម្ពុជា

EFFECT OF ECONOMIC GROWTH ON CULTURE IN CAMBODIA

*បទបង្ហាញដោយ*

បណ្ឌិត **គី សេរីវឌ្ឍន៍**

*សាស្ត្រាចារ្យ និងជាប្រធាន*
*មជ្ឈមណ្ឌលសិក្សាចិន នៃ*
*រាជបណ្ឌិត្យសភាកម្ពុជា*

# សន្និសីទអន្តរជាតិ
# ស្តីពី
# «តម្លៃវប្បធម៌អាស៊ីប៉ាស៊ីហ្វិកៈ វប្បធម៌, ប្រវត្តិ និងអនាគតភាព»

*ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨, ក្រុងសៀមរាប, ខេត្តសៀមរាប*

## ឥទ្ធិពលនៃកំណើនសេដ្ឋកិច្ចលើវប្បធម៌នៅកម្ពុជា

EFFECT OF ECONOMIC GROWTH ON CULTURE IN CAMBODIA

*បទបង្ហាញដោយ*
បណ្ឌិត **គី សេរីវឌ្ឍន៍**
*សាស្ត្រាចារ្យ និងជាប្រធានមជ្ឈមណ្ឌលសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា*

### ១-សេចក្តីផ្តើម

ការលូតលាស់នៃសេដ្ឋកិច្ចបានកែប្រែសង្គម និងការរស់នៅរបស់មនុស្សបន្តិចម្តងៗ តាមរយៈសមាហរណកម្មសេដ្ឋកិច្ចចូលទៅក្នុងតំបន់និងពិភពលោក ដែលប្រែក្លាយពីសង្គមបុរាណ ឱ្យទៅជាសង្គមទំនើប និងស៊ីវិល័យ។ ការប្រែប្រួលរបស់សង្គម និងការរស់នៅផ្តោតទៅចំណុច គន្លឹះបីគឺ ចំណេះដឹង (Knowledge) តម្លៃ (Value) និងប្រពៃណី (Tradition)។ សង្គម-វប្បធម៌របស់កម្ពុជាក៏មានការផ្លាស់ប្តូរតាមរយៈកំណើនសេដ្ឋកិច្ចប្រមាណ ៦%[1] ថេរ ក្នុងរយៈ ពេល១៥ឆ្នាំចុះក្រោយនេះ។ សក្តានុពលរបស់កម្ពុជា ក្នុងតំបន់អាស៊ាន គឺជាប្រទេសផ្តល់នូវការអនុគ្រោះដល់វិស័យទេសចរ និងអាចក្លាយជាកន្លែងណាត់ជួយគ្នាដើម្បីកិច្ចការសេដ្ឋកិច្ច។ កម្ពុជា ជាប្រទេសដែលមានការលូតលាស់សេដ្ឋកិច្ចយ៉ាងលឿន មានចំណូលសរុបកើនដល់ ២២,២ ប៊ីលានដុល្លារ គិតតាមថ្លៃបច្ចុប្បន្ន ហើយប្រជាជនម្នាក់មានចំណូលជាមធ្យមប្រចាំឆ្នាំ ១.៤៣៤ដុល្លារអាម៉េរិកនៅឆ្នាំ២០១៧ ហើយនៅក្នុងឆ្នាំ២០១៨ នេះ ចំណូលមធ្យមត្រូវបានប៉ាន់ស្មានដោយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។ កម្ពុជា បានក្លាយជា សេដ្ឋកិច្ច «ខ្លា» ដែលបានប្រសិទ្ធនាមដោយធនាគារពិភពលោក និងបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅឆ្នាំ២០១៧។ ប្រទេសនេះ មានអត្រាកំណើនសេដ្ឋកិច្ចពិតថេរ ៧%ក្នុងមួយឆ្នាំ សម្រាប់រយៈពេល៥ឆ្នាំចុងក្រោយនេះ រួមទាំងអត្រាអតិផរណាទាបប្រហែល ៣% ជាមធ្យមគិតត្រឹមឆ្នាំ២០១៦ និង ៣,៨% នៅឆ្នាំ២០១៧នេះ ។

---

[1] អ្នកនិពន្ធគណនាតាមមធ្យមធរណីមាត្រ

វិយោគមានការកើនឡើងដល់ ៥,៨៨ប៊ីលានដុល្លារ ត្រូវជា ២៩,៤% នៃផលិតផលក្នុងស្រុកសរុប ក្នុងនោះ វិនិយោគដែលបានមកពីវិស័យឯកជនចំនួន ៣៨៧៩លានដុល្លារ និងវិនិយោគមានមកពីរដ្ឋចំនួន ១៣៤៣លានដុល្លារ។ ចំណែកឯកចំនួនភ្ញៀវទេសចរណ៍ដែលមកទស្សនានៅកម្ពុជាមានប្រមាណ ៥,៥លាននាក់ ដែលចំនួននេះបាននាំមកនូវការរីកដុះដាលនៃសហគមន៍ទេសចរ សណ្ឋាគារ ភោជនីយដ្ឋាន និង សេវាកម្មទេសចរណ៍នានា។

ក្រាហ្វទី១៖ ចំនួនភ្ញៀវទេសចរមកទស្សនានៅកម្ពុជា (ពាន់លាននាក់)




(ប្រភព៖ ក្រសួងទេសចរណ៍, Tourist Statistics Report 2017)

ក្រាហ្វទី២៖ វិនិយោគផ្ទាល់ពីបរទេស ឆ្នាំ២០១៧ (លានដុល្លារ)




(ប្រភព៖ ធនាគារជាតិនៃកម្ពុជា)

របត់នៃការចូលមករបស់អ្នកវិនិយោគពីបរទេស និងភ្ញៀវទេសចរ ជាចរន្តមួយរុញច្រានឱ្យសង្គមវប្បធម៌របស់កម្ពុជាមានការផ្លាស់ប្តូរបន្តិចម្តងៗដោយស្ងៀមស្ងាត់។ ទំនាក់ទំនងរវាងប្រាក់ចំណូលនឹងការរីកដុះដាល និងផ្សព្វផ្សាយនៃវប្បធម៌មានទំនាក់ទំនងស្របគ្នា។ អ្នកស្រាវជ្រាវជាច្រើនបានរកឃើញថា នៅពេលមានចំណូលតិច

រដ្ឋាភិបាល សង្គមជាតិ គ្រួសារនីមួយៗ ក៏ដូចជាមនុស្សគ្រប់រូបត្រូវគិតគូរលើការបំពេញនូវសេចក្ដីត្រូវការចាំបាច់សិន ដូចជាអាហារ សម្លៀកបំពាក់ និងជំរក។ នៅពេលចំណូលចាប់ផ្ដើមកើនឡើងលើសពីគ្រប់គ្រាន់  នោះគេចាប់ផ្ដើមគិតទៅលើការអនុវត្តប្រតិបត្តិនូវប្រពៃណីទំនៀមទំលាប់។ លុះដល់ចំណូលកាន់តែខ្ពស់ ប្រជាជាតិមួយនឹងគិតគូរលើការផ្សព្វផ្សាយ និងពង្រីកវប្បធម៌របស់ខ្លួននៅក្នុងតំបន់ និងពិភពលោក តាមរយៈកម្មវិធីផ្លាស់ប្ដូរនិស្សិត ផ្លាស់ប្ដូរវប្បធម៌ កម្មវិធីទូរទស្សន៍ ការផ្សាយពាណិជ្ជកម្មផលិតផល ភ្ញៀវទេសចរ សេវាកម្មទេសចរណ៍ ផលិតផលទេសចរ និងការនាំចេញទំនិញចេញក្រៅប្រទេស។

## ២- ការផ្លាស់ប្ដូរជំនឿ

ជំនឿក្នុងសង្គមខ្មែរ បានបន្តជាមរតកដល់កូនចៅគ្រប់ជំនាន់ ដូចជាការជឿលើអារក្ស អ្នកតាព្រៃភ្នំ ការបន់ស្រន់ ការសែនព្រេនជាដើម។ ការបន់ស្រន់នូវអ្វីដែលយើងមើលមិនឃើញ ត្រូវបានប្រជាពលរដ្ឋកម្ពុជារក្សាទុកជាជំនឿតកូនចៅមក។ រហូតមកដល់បច្ចុប្បន្ននេះ របត់សេដ្ឋកិច្ចមានការផ្លាស់ប្ដូរជំនឿនេះត្រូវបានកាត់បន្ថយនៅក្នុងតំបន់ដែលមានប្រាក់ចំណូលខ្ពស់ ដែលយើងសង្កេតឃើញថាមានទំនាក់ទំនងស្របគ្នា។

ក្នុងករណីជាក់ស្ដែង ក្នុងពេលមានគភ៌ ស្ត្រីជាម្ដាយត្រូវប្រកាន់នូវជំនឿជាច្រើន ដូចជាការដាក់នូវអកកំបោរលើក្បាលដំណេក ដើម្បីកុំឱ្យរាហ៍កន្លង (រាហូចាប់ចន្ទ្រ)។ ក្នុងករណីជិតសម្រាល ប្រជាពលរដ្ឋបានអុចធូបបន់ស្រន់ដល់អ្នកអ្នកតា វត្ថុស័ក្តិសិទ្ធិ ដើម្បីឱ្យជួយថែរក្សាមាតា និងទារកដែលកំពុងសម្រាលឱ្យបានសេចក្ដីសុខដោយមិនដឹងពីស្ថានភាពនៃទារកក្នុងផ្ទៃ។ ជាក់ស្ដែងនៅក្នុងប្រាសាទបាយ័ន មានល្អាងមួយសម្រាប់បន់ស្រន់ពេលសម្រាលកូន។ ប៉ុន្តែផ្ទុយទៅវិញ ការសម្រាលកូននាយុគសម័យបច្ចេកវិទ្យា បានធ្វើឱ្យមាតា និងទារក ទទួលបាននូវការពិនិត្យថែទាំសុខភាពបានកាន់តែប្រសើរ ដោយបានធ្វើឱ្យប្រជាពលរដ្ឋ ផ្លាស់ប្ដូរពីជំនឿលើអ្នកតា មកជឿលើគ្រូពេទ្យទៅវិញ។ លើសពីនេះទៀត ក្នុងករណីជំងឺផ្សេងៗក៏ដូចគ្នាដែរ សង្គមកម្ពុជាបច្ចុប្បន្នបានផ្លាស់ប្ដូរមករកគ្រូពេទ្យមុន លុះដល់ដំណាក់កាលចុងក្រោយនៃជំងឺដែលគ្រូពេទ្យជួយមិនបាន ទើបបានស្វែងរកជំនឿលើអ្នកតានិងធ្វើការសែនព្រេនតាមក្រោយ។




ការផ្លាស់ប្តូរពីការជឿលើអ្នកតា ឬវត្ថុស័ក្តិសិទ្ធិ មកជឿលើវិទ្យាសាស្រ្តវិញ ដោយសារតែលទ្ធផលនៃការរីកចម្រើននៃសេដ្ឋកិច្ច និងវិទ្យាសាស្រ្ត បាននាំមកនូវសេចក្តីសុខជូនប្រជាពលរដ្ឋកម្ពុជា។ ប៉ុន្តែក្នុងករណីខ្លះទៀត ជំនឿក៏មានការកើនឡើងវិញក្នុងករណីសេដ្ឋកិច្ចមានការរីកចម្រើន ដូចជាករណីបន់ស្រន់សុំសេចក្តីសុខពេលធ្វើដំណើរ។ នៅពេលសេដ្ឋកិច្ចអន់ថយ ផ្លូវធ្វើដំណើរមានស្ថានភាពលំបាក គ្រោះថ្នាក់ចរាចរកើនមានឡើងតិចតួច គ្មានប្រជាពលរដ្ឋ ឬអ្នកធ្វើដំណើរណាម្នាក់ទៅបន់ស្រន់ទេ។ លុះដល់ស្ថានភាពផ្លូវល្អប្រសើរ ចំនួនគ្រោះថ្នាក់ចរាចរកើតមានឡើងកាន់តែច្រើន ដោយសារការបើកបរហួសល្បឿនមិនគោរពច្បាប់ បានធ្វើឱ្យមានកន្លែងបន់ស្រន់ដើម្បីសុំសេចក្តីសុខក្នុងការធ្វើដំណើរ។



## ៣-ការផ្លាស់ប្តូររចនាបទ

សេដ្ឋកិច្ចរីកចម្រើន រចនាបទនៃលំនៅឋានមានការផ្លាស់ប្តូរ ដោយការការនាំចូលគ្រឿងសំណង់ពីក្រៅប្រទេស ជាពិសេសពីប្រទេសថៃ ដែលធ្វើឱ្យលំនៅដ្ឋានរបស់ប្រជាពលរដ្ឋកម្ពុជា ប្តូររចនាបទស្រដៀងនឹងរចនាបទលំនៅដ្ឋាននៃប្រទេសថៃ ជាពិសេសប្រជាពលរដ្ឋនៅខេត្តព្រៃវែង។





ចំណាកស្រុកទៅក្រៅប្រទេស ធ្វើឱ្យរចនាបទក្នុងសង្គមមានការផ្លាស់ប្តូរ ក្រៅពីលំនៅដ្ឋាន គឺការស្លៀកពាក់និងការរៀបចំខ្លួនរបស់យុវជនមានការផ្លាស់ប្តូរតាមសម័យកាល។ សូម្បីតែជនជាតិភាគតិចក៏មានការផ្លាស់ប្តូរនូវរចនាបទរបស់ខ្លួនដែរ។

ការផ្លាស់រចនាបទលំនៅដ្ឋាន រចនាបទនៃការស្លៀកពាក់ គឺអ្នកប្រើប្រាស់ទាំងអស់ងាកទៅរកភាពទាន់សម័យ ដែលគេហៅថាទំនោរតាមគ្នាទៅរកអ្វីដែលថ្មី អ្វីដែលប្លែក ជាពិសេសចម្លងតាមនូវរចនាបទនៃប្រទេសរីកចម្រើនជាងខ្លួន។





ការផ្លាស់ប្តូរនូវរចនាបទទាំងអស់នេះ កើតចេញមកពីការស្វែងរកប្រាក់ចំណូលរបស់ក្រុមហ៊ុននានា ជាពិសេសតារាចំរៀង ពិធីករ ពិធីការនី ដែលចង់បានប្រជាប្រិយភាពក្នុងគោលដៅស្វែងរកប្រាក់ចំណូលគួបផ្សំនឹងប្រព័ន្ធផ្សព្វផ្សាយដែលមិនសូវបានយកចិត្តទុកដាក់បានល្អិតល្អន់។

## ៤-ការផ្លាស់ប្តូរការអប់រំ

ការសិក្សាក៏មានការផ្លាស់ប្តូរទៅតាមការលូតលាស់នៃសេដ្ឋកិច្ច គឺសាលារៀននិងសម្ភារសិក្សាក៏មានការផ្លាស់ប្តូរដែរ។ ក្នុងយុគសម័យដែលទើបងើបចេញពីរបបប៉ុលពត សិស្សខ្មែរគ្មានថ្នាក់រៀនគ្រប់គ្រាន់ គ្មានតុកៅអីនិងសម្ភារសិក្សាគ្រប់គ្រាន់ទេ។ បច្ចុប្បន្នកំណើនសេដ្ឋកិច្ចបានធ្វើឱ្យប្រព័ន្ធអប់រំមានការផ្លាស់ប្តូរពីការចូលរៀនដោយឥតបង់ថ្លៃ មកសាលារៀនដោយបង់ថ្លៃ។ នេះបង្ហាញពីភាពលូតលាស់នៃសេដ្ឋកិច្ចដែលមានកំណើនលទ្ធភាពនៃការបង់ថ្លៃសាលារៀនដល់កូនប្រុសស្រីឱ្យងាកចេញពីសាលាដែលមានការទទួលខុសត្រូវលើការសិក្សាតិច ទៅរកសាលាដែលមានការទទួលខុសត្រូវលើការសិក្សារបស់សិស្សខ្ពស់ ជាពិសេសគឺសាលាឯកជនដែលកំពុងប្រកួតប្រជែងគ្នាលើទីផ្សារសេវាអប់រំ។




ការប្រើប្រាស់ទូរស័ព្ទចល័តទំនើបក្នុងថ្នាក់រៀនជាជំនួយដល់ការសិក្សារបស់សិស្ស និស្សិតផងដែរ។ កំណើននៃសេដ្ឋកិច្ច បានធ្វើឱ្យនិស្សិតអាចទទួលបាននូវប្រើប្រាស់ទូរស័ព្ទ ទំនើប ដើម្បីជាជំនួយដល់ការរៀនសូត្រ ជាពិសេសអាចភ្ជាប់ទៅនឹងបណ្តាញអ៊ីនធើណែត។ និស្សិតអាចប្រើទូរស័ព្ទទំនើបក្នុងការស្រាវជ្រាវរកព័ត៌មាន ទាក់ទងនឹងខ្លឹមសារមេរៀន ការធ្វើកិច្ចការស្រាវជ្រាវរបស់សាលា និងចែករំលែកព័ត៌មានគ្នាទៅវិញទៅមក។





ទោះជាយ៉ាងណា និស្សិតភាគច្រើន ប្រើប្រាស់ឧបករណ៍អេឡិចត្រូនិច ដូចជាទូរស័ព្ទទំនើប  កុំព្យូទ័រ ឬ Tablet ដើម្បីលេងហ្គេមក្នុងម៉ោងសិក្សា ឬប្រើប្រាស់បណ្តាញសង្គម ដូចជា ហ្វេសប៊ុកជាដើម ក្នុងម៉ោងសិក្សាដែលធ្វើឱ្យកម្រិតនៃការយកចិត្តទុកដាក់លើការសិក្សាធ្លាក់ចុះដោយមិនដឹងខ្លួន។

ដោយសារការផ្លាស់ប្តូរលឿននៃសេដ្ឋកិច្ច ធ្វើនិស្សិតមួយចំនួនឈ្លក់វង្វេងនឹងការប្រើប្រាស់ទូរស័ព្ទទំនើបហួសហេតុដែលជាការរំខានដល់ការសិក្សាតាមរយៈការចូលដេកយប់ជ្រៅ ការលួចប្រើប្រាស់ទូរស័ព្ទក្នុងពេលគ្រូពន្យល់មេរៀន នឹងក្លាយទៅមនុស្សញៀននឹងទូរស័ព្ទ ហើយការញៀនប្រើប្រាស់ទូរស័ព្ទអាចធ្វើឱ្យមានការផ្លាស់ប្តូរនូវរបៀបរបបរស់នៅនឹងការប្រាស័យទាក់ទងគ្នាទៀត។

## ៥-ការផ្លាស់ប្តូរទម្លាប់នៃការរស់នៅ

បើសិនជាយើងក្រឡេកមើលពីការរស់នៅរបស់យុវជនក្នុងសម័យសេដ្ឋកិច្ចខ្លារបស់កម្ពុជា មានការផ្លាស់ប្តូរខ្លាំង។ ភាពស្និទ្ធស្នាលក្នុងចំណោមគ្រួសារបានបាត់បង់យ៉ាងច្រើន ក្នុងខណៈដែលឪពុកម្តាយអនុញ្ញាតឱ្យកូនរបស់ខ្លួនលេងទូរស័ព្ទ និងលេងហ្គេមតាមទូរស័ព្ទនៅក្នុងវ័យកុមារ។ កុមារទាំងនេះ បានចាត់ទុកថា ខ្លួនជាអ្នកគ្រប់គ្រងហ្គេមនេះ ជាអ្នកគ្រប់គ្រងស្ថានការណ៍ គ្មានអ្នកណាគ្រប់គ្រងលើគាត់ទេ។ នេះ ជាកត្តាធ្វើឱ្យកូនមិនសូវស្តាប់នូវការណែនាំរបស់ឪពុកម្តាយ។

ក្នុងពេលជួបជុំពិសាអាហារ កូនមិនសូវបាននិយាយទៅកាន់ឪពុកម្តាយទេ ដោយជាប់ការប្រើប្រាស់ពេលវេលានេះ ដើម្បីបណ្តាញសង្គម ឬលេងហ្គេម។ មានករណីខ្លះទៀត កូននោះបានយកអាហារទៅបរិភោគនៅក្នុងបន្ទប់ដោយឡែកដោយមិនជួបប្រាស័យទាក់ទងនឹងក្រុមគ្រួសារ។

ភាពស្និទ្ធស្នាលរវាងមិត្តភ័ក្តិ បានកាត់បន្ថយឆ្ងាយបន្តិចម្តងៗនិងក្លាយជាមនុស្សរស់នៅដោយឯកឯង។

  

ចំណែកឯការបំពុលសង្គមតាមបណ្ដាញសង្គម ក៏មានផលប៉ះពាល់ជាអវិជ្ជមានដល់កាលលូតលាស់នៃសេដ្ឋកិច្ច។ ករណីព័ត៌មានខុសការពិតតាមហ្វេសប៊ុកដែលបានបង្កើតដោយជនខិលខូចក្នុងចេតនាទុច្ចរិតបានធ្វើប្រជាពលរដ្ឋជឿ។ ករណីមួយទៀតដែរ គឺក្រុមអ្នកសារព័ត៌មានដែលសរសេរទំព័រមុខឱ្យមានការទាក់ទាញបានធ្វើឱ្យពលរដ្ឋមួយចំនួនដែលមិនបានអានច្បាស់លាស់ មិនបានគិតពិចារណាត្រឹមត្រូវ បានចែកផ្សាយតគ្នាជាព័ត៌មានបំភាន់រហូតដល់មានការនិយាយតគ្នាតាមតុកាហ្វេទៀតផង។

## ៦-សន្និដ្ឋាន

បើយើងក្រឡេកមកមើលរដ្ឋាភិបាលវិញ សេដ្ឋកិច្ចកាន់តែមានការលូតលាស់ រដ្ឋាភិបាលនៃប្រទេសនីមួយៗតែងតែជំរុញនូវវិស័យវប្បធម៌របស់ខ្លួនឱ្យកាន់តែរីកសាយភាយ ដូចជាការចុះបញ្ជីនៃបេតិកភណ្ឌជាតិនានាឱ្យចូលក្នុងបេតិកភណ្ឌពិភពលោកដើម្បីទាក់ទាញ និងទទួលបាននូវកំណើនភ្ញៀវទេសចរណ៍។

ការបង្កើតឱ្យមានពិពណ៌វប្បធម៌ មិនត្រឹមតែជាការផ្សព្វផ្សាយពាណិជ្ជកម្មជាតិសម្រាប់វិស័យទេសចរណ៍ប៉ុណ្ណោះទេ តែជាការបង្ហាញពីការយល់គ្នាទៅវិញទៅមកលើពិភពលោកដើម្បីភាពសុខដុមរមនាតាមរយៈការយល់គ្នាលើវប្បធម៌ ការអត់ឱនឱ្យគ្នាតាមទម្លាប់នៃការរស់នៅដែលមិនដូចគ្នា។

កត្តាចម្បងនិងឫសគល់នៃបញ្ហាទាំងនេះ គឺចំណេះដឹងនៃប្រជាពលរដ្ឋនៅមានកម្រិត សូម្បីតែនិស្សិតក្នុងមហាវិទ្យាល័យក៏ដោយ។ ការរិះគន់សង្គមខ្លាំង កើតចេញពីការផ្សព្វព័ត៌មានតាមបែបទាក់ទាញអ្នកអាន ធ្វើឱ្យប៉ះពាល់សណ្ដាប់ធ្នាប់សង្គម។ ក្នុងករណីចំណេះដឹងមានកម្រិត ប្រព័ន្ធផ្សព្វផ្សាយមិនគួរដាក់ចំណងខ្លះធ្វើឱ្យមានការភាន់ច្រឡំទេ។

រដ្ឋាភិបាលគួរយកចិត្តទុកដាក់ លើការអប់រំទស្សនវិជ្ជាឱ្យខ្លាំងជាងនេះ ព្រោះទស្សនវិជ្ជាសង្គមរបស់កម្ពុជាហាក់មានការចុះខ្សោយ។ គុណភាពចំណេះដឹងគួរតែត្រូវបានយកចិត្តទុកដាក់ដើម្បីឱ្យយុវជនអាចឈានដល់កម្រិតមួយ ចេះស្វែងយល់និងពិចារណារកខុសត្រូវដោយខ្លួនឯងបាន។

រដ្ឋាភិបាលក៏គួរយកចិត្តទុកដាក់លើការរៀបចំឱ្យមានវិស័យវប្បធម៌ក្នុងវិស័យអប់រំ ជាពិសេសចាប់ផ្ដើមចេញពីបឋមសិក្សារហូតដល់មហាវិទ្យាល័យ ព្រោះមហាវិទ្យាល័យនៅកម្ពុជាបច្ចុប្បន្ន គឺជាក្រុមហ៊ុនអាជីវកម្មសុទ្ធសាធ ដែលមិនមានកម្មវិធីវប្បធម៌ក្នុងនោះទេ។ គួរបង្កើតឱ្យមានពិពណ៌វប្បធម៌ ពិពណ៌សៀវភៅ នៅតាមមហាវិទ្យាល័យផងដែរ៕